**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងរដ្ឋប្បវេណីលេខ ១៦៩
ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០
សាលក្រមលេខ ០០៦ ស.រ.ណ/២០
ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០

# នាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្តាល

បានបញ្ចប់នីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ០៩ ព្រឹក ដោយមានសមាសភាពចូលរួម៖

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

**ដើមចោទឈ្មោះ** [redacted] **វិទូ** ភេទប្រុស កើតឆ្នាំ ១៩៨៤ មានអាសយដ្ឋានបច្ចុប្បន្ននៅ [redacted] មានអ្នកតំណាងដោយអាណត្តិ លោកមេធាវី [redacted] និងលោកមេធាវី [redacted] ។

**ចុងចម្លើយឈ្មោះ** [redacted] **កក្កដា** ភេទស្រី កើតឆ្នាំ ១៩៨៩ មានអាសយដ្ឋានបច្ចុប្បន្ននៅ [redacted] ។

**ខ្លឹមសារសាក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ**

១. ឱ្យដើមចោទឈ្មោះ [redacted] **វិទូ** និង ចុងចម្លើយឈ្មោះ [redacted] **កក្កដា** លែងលះនឹងគ្នា ។

២. សុំប្រគល់សិទ្ធិគ្រប់គ្រង និង មានអំណាចមេបាលើកូនឈ្មោះ [redacted] **ពេជ្រជូលីណា** ភេទស្រី កើតថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ ឱ្យភាគីចុងចម្លើយ ។

៣. សុំបែងចែកទ្រព្យសម្បត្តិរួម ។

## អង្គហេតុ និង ចំណុចវិវាទ

**១. ពន្យល់ត្រួសៗអំពីរឿងក្តី**

ដើមចោទឈ្មោះ [redacted] **វិទូ** និង ចុងចម្លើយឈ្មោះ [redacted] **កក្កដា** បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និង បានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ០២ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ សៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០១៤ ដោយការរួមរស់ជាមួយគ្នា មានកូនស្រីម្នាក់ឈ្មោះ [redacted] **ពេជ្រជូលីណា** ភេទស្រី កើតថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ ។ ក្នុងការនៅជាមួយគ្នាពុំសូវចុះសម្រុងនិងគ្នា ដោយមានរឿងរកាំរកូសនឹងគ្នាញឹកញាប់ជាហេតុធ្វើឱ្យដើមចោទអស់មនោសញ្ចេតនាអាណិតស្រលាញ់គ្នាជាប្តីប្រពន្ធ ។

[redacted]

Scanned with CamScanner

២. ចំណុចវិវាទ តើការអះអាងរបស់ដើមចោទត្រឹមត្រូវឬទេ ?

**៣. ការអះអាងរបស់ដើមចោទ**

អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ និង ដើមចោទ បានថ្លែងការណ៍ថា រក្សាខ្លឹមសារការទាមទារដូចនៅក្នុងពាក្យបណ្ដឹង ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ ។ ម្យ៉ាងវិញទៀត ដើមចោទបានធ្វើសេចក្ដីថ្លែងការណ៍បញ្ជាក់បន្ថែមថា ដើមចោទ និង ចុងចម្លើយ រស់នៅមិនចុះសម្រុងនឹងគ្នា ហើយអស់មនោសញ្ចេតនាជាប្តីប្រពន្ធទើបសុំឱ្យតុលាការសម្រេចលែងលះ ។ ម៉្យាងវិញទៀត ដើមចោទ សុំសិទ្ធិគ្រប់គ្រងកូនស្រី ឈ្មោះ[redacted]ពេជ្យជូលីណា កើតថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ ដោយសារបច្ចុប្បន្នកូនស្រីនេះ កំពុងរស់នៅជាមួយដើមចោទ ។ ចំពោះអចលនទ្រព្យ ដែលដើមចោទទាមទារឱ្យតុលាការ សម្រេចនោះ ដើមចោទឈ្មោះ[redacted]វិទូ មិនធ្វើការទាមទារទេ ដោយសារតែខ្វះឯកសារ ។

**៤. ការអះអាងចុងចម្លើយ** (អវត្តមាន)

៤. **ភស្តុតាងមានដូចជា**

- សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ ០២ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ សៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០១៤ រវាងឈ្មោះ [redacted] **វិទូ** និងឈ្មោះ [redacted] **កក្កដា** ។ (ច្បាប់ដើម)
- សំបុត្របញ្ជាក់កំណើត លេខ ២៧៥ ចុះថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០១២ សៀវភៅបញ្ជាក់កំណើត លេខ ០៣ របស់ឈ្មោះ[redacted]**ពេជ្រជូលីណា** ។ (ថតចម្លង)
- កិច្ចព្រមព្រៀងលែងលះដើមចោទឈ្មោះ [redacted] **វិទូ** និងចុងចម្លើយឈ្មោះ [redacted] **កក្កដា** ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៦ ។

## សំអាងហេតុ

១. យោងតាមសំបុត្រអាពាហ៍ពិពាហ៍លេខ ០២ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ សៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០១៤ អាចបញ្ជាក់បានថា ដើមចោទឈ្មោះ [redacted] **វិទូ** និង ចុងចម្លើយឈ្មោះ[redacted]**កក្កដា** ជាសហព័ន្ធនឹងគ្នាត្រឹមត្រូវតាមច្បាប់ ។ ប៉ុន្តែក្នុងការរស់នៅជាមួយគ្នារវាង ដើមចោទ និង ចុងចម្លើយ រស់នៅមិនចុះសម្រុងគ្នា ដែលនាំឱ្យអស់មនោសញ្ចេតនានឹងគ្នា ។ ដូចនេះ តុលាការ យល់ឃើញថា មានមូលហេតុនៃការលែងលះ ស្របតាមបញ្ញត្តិមាត្រា ៩៧៨ កថាខណ្ឌទី១ ចំណុច ង នៃក្រមរដ្ឋប្បវេណី ។

២. នៅក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់ ដើមចោទស្នើសុំ ជាអ្នកមានអំណាចមេបាលើកូនជាអនីតិជន ឈ្មោះ[redacted] **ពេជ្យជូលីណា** ហើយបច្ចុប្បន្នកូនដែលជាអនីតិជនកំពុងរស់នៅជាមួយដើមចោទដែលត្រូវជាឪពុក ។ ដូចនេះ តុលាការគប្បីសម្រេចឱ្យដើមចោទជាអ្នកមានអំណាចមេបាលើកូនជាអនីតិជន ដើម្បីផលប្រយោជន៍របស់កូននោះ ស្របតាមបញ្ញត្តិមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី ។

[redacted]

Scanned with CamScanner

៣. យោងតាមពាក្យបណ្ដឹង ដើមចោទ បានទាមទារឱ្យបែងចែកទ្រព្យសម្បត្តិរួម ។ ប៉ុន្តែនៅក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទ សម្រេចមិនទាមទារវិញ ដោយហេតុថាគ្មានឯកសារគ្រប់គ្រាន់ ។ ដូចនេះ តុលាការគប្បីប្រានចោលការទាមទារនេះ ។

៤. តុលាការនឹងពិចារណាអំពីបន្ទុកប្រាក់ប្រដាប់ក្ដី ស្របតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធី រដ្ឋប្បវេណី ។

## សេចក្ដីសម្រេចបញ្ចប់

១. ឱ្យដើមចោទឈ្មោះ [redacted] វិទូ និង ចុងចម្លើយឈ្មោះ [redacted] ន្ទ កក្កដា លែងលះគ្នា ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ ០២ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ សៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០១៤ ។

២. ឱ្យដើមចោទឈ្មោះ [redacted] វិទូ ជាអ្នកមានអំណាចមេបាលើកូនជាអនីតិជនឈ្មោះ [redacted] ពេជ្រផូលីណា ភេទស្រី កើតថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ ។

៣. ប្រានចោលការទាមទារចំណុចទី ៣ នៃខ្លឹមសារសាលក្រម ដែលដើមចោទ ទាមទារឱ្យតុលាការចេញ ។

៤. បន្ទុកប្រដាប់ក្ដីជារបស់ចុងចម្លើយ ។

សាលក្រមនេះ ចំពោះមុខដើមចោទ ប៉ុន្តែកំបាំងមុខចុងចម្លើយ ។ ទុកសិទ្ធិប្ដឹងទាស់ និង ប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ថ្ងៃអង្គារ ០៤កើត ខែកត្ដិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
កណ្ដាល, ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០
**ចៅក្រម**
ហត្ថលេខា និង ត្រា [redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃអង្គារ ០៤កើត ខែកត្ដិក ឆ្នាំជូត ទោស័ក ព.ស២៥៦៤
កណ្ដាល, ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០
**ក្រឡាបញ្ជី**
[redacted]

បានឃើញ
**ចៅក្រម**
[redacted]

[redacted]